# ជីវិតអន្ធការ

ភាពងងឹតអន្ធការ មិនមែនជារបស់ដែលអ្នកណាម្នាក់បង្កើតមកទេ ជារបស់ដែលធម្មតាប្រចាំលោកនេះឲ្យតែទីណាខ្វះពន្លឺ ងងឹតក៏នឹងមាននៅក្នុងទីនោះ។

អវិជ្ជា ក៏ជាធម្មជាតិម៉្យាង កើតអាស្រ័យនឹងជីវិតសត្វលោកគ្រប់គ្នា វៀរលែងតែបុគ្គលដែលបានសម្រេចជាព្រះអរហន្ត។

តាមន័យនៃបដិច្ចសមុប្បទសម្តែងថា អវិជ្ជា គឺជាមេនៃសង្ខារធម៌ទាំងឡាយ បើនិយាយឲ្យងាយស្តាប់ អវិជ្ជា គឺជាមេនាំអាទ៏ឲ្យមានតួជីវិតនេះឯង។

អវិជ្ជា ដែលជាស្បែងងឹតនៃជីវិតមាន ៨ យ៉ាងគឺ

១. **ទុក្ខេ អញ្ញាណំ** មិនដឹងក្នុងសេចក្តីទុក្ខ គឺមិនដឹងក្នុងទុក្ខទាំង ១២ កងមានជាតិទុក្ខជាដើម ដែលជាទុក្ខសច្ចៈ។

២. **ទុក្ខសមុទយេ អញ្ញាណំ** មិនដឹងនូវធម៌ដែលជាហេតុនាំឲ្យកើតទុក្ខ គឺមិនដឹងនូវតណ្ហា សេចក្តីប្រាថ្នា គ្រប់យ៉ាង ដែលជាទុក្ខសមុទយសច្ចៈ។

៣. **ទុក្ខនិរោធេ អញ្ញាណំ** មិនដឹងនូវព្រះនិពាន្វ ជាទីរលត់នូវសេចក្តីទុក្ខដែលជានិរោសច្ចៈ។

៤. **ទុក្ខនិរោគាមិនីបដិបទាយ អញ្ញាណំ** មិនដឹងនូវផ្លូវជាទីចូលទៅរំលត់នូវសេចក្តីទុក្ខដែលជាមគ្គសច្ចៈ។

៥. **បុព្វន្តាបរន្តេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងខន្ធអាយតនៈ ធាតុ ដែលជាអតីត គឺមិនដឹងនូវជាតិកំណើត ដែលធ្លាប់កើតក្នុងជាតិមុនៗ។

៦. **អបរន្តេ អញ្ញាណំ** សេចក្តីមិនដឹងក្នុងខន្ធ អាយតនៈ ធាតុ ដែលជាអនាគត គឺមិនដឹងនូវជាតិកំណើត ដែលនិងកើតតទៅក្នុងជាតិខាងមុខៗទៀត។

៧. បុព្វបរន្តេ អញ្ញាណំ សេចក្តីមិនដឹងក្នុងខន្ធអាយតនៈ ធាតុ ទាំងក្នុងអតីត ទាំងក្នុងអនាគត។

៨. ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ សេចក្តីមិនដឹងក្នុងនាមរូប ដែលកើតឡើងដោយអាស្រ័យហេតុបច្ច័យ តាមន័យក្នុងបដិច្ចសមុប្បាទ។

ធម៌ដែលលើកមកសំដែងនេះ មានជម្រៅណាស់ទាល់តែស្តាប់ និងសិក្សាស្រាវជ្រាវច្រើនទើបមិនមានការ យល់ខុស បើនិយាយយកន័យដោយខ្លី សំដៅយកអវិជ្ជា ដែលមិនដឹងក្នុងលក្ខណៈ ៣ យ៉ាងគឺ

១. មិនដឹងថា ជីវិតគឺជាអ្វី
២. មិនដឹងថាហេតុនាំឲ្យកើតជីវិត
៣. មិនដឹងថា ជីវិតគឺជាផលរបស់ហេតុ

អវិជ្ជាទាំងនេះ មិនមែនមានសម្រាប់តែអ្នកមិនកាន់សាសនា ឬសម្រាប់តែអ្នកកាន់សាសនាផ្សេងៗនោះទេ សូម្បីតែអ្នកកាន់ព្រះពុទ្ធសាសនាក៏ដោយ ដរាបណានៅក្នុងភាពជាបុថុជ្ជន តែងតែមានគ្រប់គ្នាទាំងអស់ ប្លែកគ្នាត្រង់ថា បើបុថុជ្ជននុះបានអាស្រ័យនឹងធម៌របស់ព្រះមានព្រះភាគច្រើន អវិជ្ជាក៏មិនសូវគ្របសង្កត់ខ្លាំង ប្រសិនបើមិនបានយកធម៌របស់ព្រះមានព្រះភាគជាទីតាំងទេ អវិជ្ជាក៏គ្របសង្កត់ខ្លាំងតាមលំដាប់ រហូតធ្វើឲ្យអ្នកនុះជឿរឿងមង្គលភ្ញាក់ផ្អើលផ្សេងៗ មានការបន់ស្រន់ ស្រោចទឹក រំដោះគ្រោះជាដើម ដែលជាជំនឿឆ្វេង ហើយផ្ទុយគ្នាស្រឡះអំពីធម៌របស់ព្រះសម្មាសម្ពុទ្ធ។

ជីវិតដែលកើតមកនេះ គឺងងឹតស្រាប់ទៅហើយ បើមាននូវសេចក្តីប្រមាថធ្វេសប្រហែសបន្ថែមទៀត តើជីវិតនឹងក្លាយទៅជាយ៉ាងណា! ព្រោះតែសត្វលោកស្ទើរតែទាំងអស់ មានជីវិតរស់នៅក្នុងភាពអន្ធការយ៉ាងនេះ ទើបព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែង ក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា លោកវគ្គថា

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ

## សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ

លោកិយមហាជននេះ ជាមនុស្សងងឹតបណ្ដាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់(នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នាណាស់ ដែលទៅកាន់ឋានសួគ៍ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ដូច្នោះ។

មានជីវិត ឥតគំនិត គិតពិចារណា៍
មិនឧស្សាហ៍ ស្រវាចាប់ ស្ដាប់ធម្មា
មច្ចុមារ រាគំនិត ជិតរហូត។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)